# សេចក្តីជូនដំណឹង
# ស្តីពី
# សំណើសុំលើកលែងលើការផ្តល់របាយការណ៍ប្រចាំត្រីមាសទី៣ របស់ធនាគារ ABA

ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់ (ធនាគារ ABA) សូមជម្រាបជូនដំណឹងដល់វិនិយោគិន និងសាធារណជន មេត្តាជ្រាបថា ធនាគារបានបោះផ្សាយលក់សញ្ញាបណ្ណសាជីវកម្មរបស់ខ្លួននៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ និងត្រូវបានចុះបញ្ជីលក់នៅផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩។ យោងតាមប្រកាសស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម លេខ ០០៧/១៨ គ.ម.ក./ប្រ.ក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ធនាគារ ABA តម្រូវឲ្យផ្តល់របាយការណ៍ត្រីមាសជូនដល់ គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ដោយរាប់ចាប់ពីរបាយការណ៍ត្រីមាសទីបីក្នុងឆ្នាំ ២០១៩ នេះតទៅ ហើយតម្រូវឲ្យផ្តល់ជូនមុនថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩។

ដោយសារមិនមានពេលគ្រប់គ្រាន់ និងធនាគារកំពុងជាប់បំពេញកិច្ចការ CIFRS សម្រាប់ឆ្នាំ២០១៩ ខាងមុខ ធនាគារ ABA ស្នើសុំលើកលែងមិនបញ្ចេញរបាយការណ៍ប្រចាំត្រីមាសទី៣ ឆ្នាំ២០១៩ នេះឡើយ។ ធនាគារ ABA នឹងធ្វើការទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយ គ.ម.ក. និង ផ.ម.ក. ក៏ដូចជាអាជ្ញាធរដទៃទៀតដើម្បីបង្ហាញព័ត៌មាន និងផ្តល់ជូនរបាយការណ៍បន្ថែម ស្របតាមបទបញ្ញត្តិដែលពាក់ព័ន្ធ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩

ធនាគារ ABA




Head Office

No. 148, Preah Sihanouk Blvd,
Sangkat Boeung Keng Kang I, Khan Chamkarmon,
Phnom Penh, Kingdom of Cambodia

Tel: (855) 23 225 333
info@ababank.com
www.ababank.com

Fax: (855) 23 216 333
P.O. Box: 2277
SWIFT: ABAAKHPP